00786737

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 03 / 2012
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

E172/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

**អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង**

សាធារណៈ / Public

ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** បច្ចុប្បន្នភាពនៅលើអនុស្សរណៈស្តីពីសវនាការលើឯកសារនៅដំណាក់កាលបន្ទាប់ (ដែលនឹងប្រព្រឹត្តនៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២)

១. បន្ថែមពីលើព័ត៌មានបានអង្គជំនុំជម្រះសាលាដំបូងបានទទួលបន្ថែមពីភាគី អង្គជំនុំជម្រះសាលាដំបូងសម្រេចចេញអនុស្សរណៈថ្មីដែលមានការកែប្រែលើអនុស្សរណៈមុនរបស់ខ្លួន E172/1។

២. ដូចដែលបានបញ្ជាក់នៅក្នុងអនុស្សរណៈ E172 របស់ខ្លួនចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២ រួចហើយថា នៅពេលអង្គជំនុំជម្រះសាលាដំបូងបន្តធ្វើសវនាការនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ខាងមុខ អង្គជំនុំជម្រះនឹងបែងចែកពេលវេលាសម្រាប់ការជំទាស់ដោយផ្ទាល់មាត់ទៅលើឯកសារទាំងឡាយដែលភាគីបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ ដែលឯកសារទាំងនោះពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង ០០២/០១ (ឯកសារ E109/1.1, E109/2.1, E109/4, E109/6.2) និងដែល

E172/5

ពុំទាន់បានលើកយកមកពិភាក្សានៅក្នុងសវនាការមកទល់ពេលបច្ចុប្បន្ន។ សវនាការផ្ទាល់មាត់ទាំងនេះធ្វើឡើងជំនួសឲ្យការដាក់សារណាជាលាយលក្ខណ៍អក្សរ។

៣. ដើម្បីងាយយោង អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថាសវនាការផ្ទាល់មាត់ទាំងនេះ នឹងធ្វើពាក់ព័ន្ធទៅនឹងប្រភេទឯកសារដែលនៅសេសសល់ខាងក្រោម ដែលជាឯកសារស្ថិតនៅក្នុងសំណុំរឿង៖

- ប្រភេទឯកសារទាំងអស់ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់មកអង្គជំនុំជម្រះ ប៉ុន្តែពុំទាន់ត្រូវបានបង្ហាញក្នុងអំឡុងសវនាការលើឯកសារកាលពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា និងថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ កន្លងមក មានជាអាទិ៍ដូចជា[1]៖

A6 – ប្រវត្តិរូបអ្នកទោសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.6 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.7 (៩១ ឯកសារ)

A7 – បញ្ជីឯកសារពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.7 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.7 (១៦៩ ឯកសារ)

A8 – សេចក្ដីរាយការណ៍ផ្សេងៗទាក់ទងនឹងស្រុកត្រាំកក់៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.8 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.8 (៥៧ ឯកសារ)

A9 – កំណត់ត្រាអ្នកទោសនៅស-២១៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.9 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.9 (២៩៧ ឯកសារ)

A10 – ចម្លើយសារភាពពីស-២១៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.10 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.10 (៣៤៥ ឯកសារ)

---

[1] តាមការរំពឹងទុក អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យផ្ទៀងផ្ទាត់ឯកសារដែលបានយោងនៅត្រង់ជើងទំព័រនៃកថាខណ្ឌនានានៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ជាមួយប្រភេទឯកសារទាំងអស់របស់សហ-ព្រះរាជអាជ្ញាដែលនឹងត្រូវពិភាក្សាក្នុងអំឡុងសវនាការចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ឯកសារដែលមានយោងនៅក្នុងដីកាដំណោះស្រាយដូចដែលបានលើកឡើងនេះគឺស្ថិតនៅក្នុងប្រភេទឯកសារទាំងនេះដែលត្រូវបានពិភាក្សារួចហើយនៅក្នុងអំឡុងសវនាការស្ដីពីឯកសារកាលពីពេលមុន។ អង្គជំនុំជម្រះនឹងពុំស្ដាប់ការជំទាស់ពាក់ព័ន្ធនឹងឯកសារដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទាំងឡាយណាដែលអង្គជំនុំជម្រះធ្លាប់បានសម្រេចកាលពីពេលមុន និងធ្លាប់ត្រូវបានដាក់ចំពោះមុខខ្លួន។ ឯកសារប្រភេទ A12 និង A13 នឹងត្រូវសម្រេចតាមរយៈការសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដែលកំពុងស្ថិតក្រោមការពិចារណារបស់អង្គជំនុំជម្រះ។ ហេតុដូច្នេះនៅដំណាក់កាលនេះ ឯកសារទាំង ០២ ប្រភេទនេះនឹងពុំត្រូវបានកំណត់យកមកដេញដោលនៅក្នុងសវនាការផ្ទាល់មាត់លើឯកសារឡើយ។

00786739

A11 – កំណត់ហេតុជាលាយលក្ខណ៍អក្សរពេលជំនុំជម្រះនៃសំណុំរឿង ០០១៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.11 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.11 (១២ ឯកសារ)

A14 – របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.14 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.14 (២ ឯកសារ)

A15 – ផែនទី និងរូបថត៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.15 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.15 (៤៦១ ឯកសារ)

A16 – ខ្សែអាត់សំឡេង និងវីដេអូ៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.16 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.16 (៣៩៨ ឯកសារ)

A17 – ទំនាក់ទំនងអន្តរជាតិ៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.17 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.17 (១៥៨ ឯកសារ)

A18 – សេចក្តីរាយការណ៍ពីសារព័ត៌មានអន្តរជាតិ៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.18 17 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.18 (៣៧២ ឯកសារ);

A19 – អត្ថបទស្រាវជ្រាវ របាយការណ៍វិភាគ និងសៀវភៅ៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31.19 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.19 (២៣១ ឯកសារ)

A20 – របាយការណ៍ស្តីពីដីកាចាត់ឲ្យស៊ើបសួរជំនួស៖ ឯកសារទាំងអស់ដែលមាននៅក្នុងឯកសារ E9/31 ដែលត្រូវបានបង្ហាញថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.20 (១១២ ឯកសារ)

- ឯកសារចំនួន ១០ ក្នុងចំណោមឯកសារចំនួន ២៥ ដែលសហមេធាវីនាំមុខបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ៧(ក)(i) ដែលត្រូវបានពិនិត្យកែសម្រួលនៅក្នុងឯកសារ E109/2.1 (ដូចដែលបានផ្ញើមកអង្គជំនុំជម្រះ និងភាគីតាមរយៈសារអេឡិចត្រូនិកពីសំណាក់សហមេធាវីនាំមុខ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារចំនួន ១៥ ដែលនៅសេសសល់ក្នុងចំណោមឯកសារទាំងនេះ ត្រូវជាន់គ្នាជាមួយឯកសារដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ ឬត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ)។ សវនាការនេះនឹងមិនពិភាក្សាអំពី "បញ្ជីឯកសារគាំទ្រទាំងអស់នៅត្រង់ផ្នែកនានានៃដីកាដំណោះស្រាយ ពាក់ព័ន្ធទៅនឹងវគ្គទាំងបួនដែលត្រូវធ្វើសវនាការនៅដំណាក់កាលដំបូង" របស់សហមេធាវីនាំមុខដូចមានរៀបរាប់នៅក្នុងឯកសារ E109/2.1 ឡើយ។ ជំនួសមកវិញ អង្គជំនុំជម្រះនឹងចាត់ការលើបញ្ជីឯកសារនេះនៅពេលក្រោយ។

00786740

- ឯកសារសេសសល់ដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ (ដែលត្រូវបានបង្ហាញអត្តសញ្ញាណនៅក្នុងឯកសារ E109/6.2 ថាជាឯកសារមានអត្តសញ្ញាណលេខ D222/1.17) (ឯកសារ D313/1.2.2 ត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយត្រូវបានចាត់ថ្នាក់ជាឯកសារ E3/88)

- ឯកសារសេសសល់ចំនួន ៧៨ ដែលមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានស្នើសុំដាក់ (ឯកសារ E109/1.1) (ឯកសារចំនួន ១០ ខាងក្រោមនេះ ត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចរាល់មានជាអាទិ៍៖ ឯកសារ D28-ឧបសម្ព័ន្ធ (E3/21), 13.2 (E3/182), D201/8 (E3/43), D200/3 (E3/64), D200/9 (E3/67), D125/160 (E3/58), D167 (E3/42), D199/20 (E3/96), D166/166 (E3/35) និង D91/9 (E3/104))។

៤. ឯកសារទាំងអស់ ដែលភ្ជាប់មកជាមួយកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្មមកទល់នឹងពេលបច្ចុប្បន្ន និងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងឡាយដែលត្រូវបានបង្ហាញអត្តសញ្ញាណនៅក្នុងអនុស្សរណៈ E172 សម្រាប់សវនាការនៅពេលបន្ទាប់ នឹងត្រូវចាត់ទុកថាបានដាក់ចំពោះមុខអង្គជំនុំជម្រះជាមួយនឹងសក្ខីកម្មរបស់បុគ្គលនោះ លើកលែងតែមានការជំទាស់ពីភាគីក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម។

៥. បន្ទាប់ពីមានកិច្ចប្រជុំក្រៅផ្លូវការរវាងភាគី ជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃ ពុធ ទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីអំពីការបែងចែកពេលវេលាសម្រាប់សវនាការលើឯកសារដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ដែលមានដូចខាងក្រោម៖

ថ្ងៃ ច័ន្ទ ទី ១២ ខែ មីនា ឆ្នាំ ២០១២៖ ការលើកសេចក្តីជំទាស់របស់មេធាវីការពារជនជាប់ចោទ នួន ជា ទៅនឹងឯកសារទាំងអស់ខាងលើ (នៅក្នុងសវនាការពេលរសៀល, បន្ទាប់ពីក្រឡាបញ្ជីអានកថាខណ្ឌនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវធ្វើសវនាការនៅវគ្គបន្ទាប់)

ថ្ងៃ អង្គារ ទី ១៣ ខែ មីនា ឆ្នាំ ២០១២៖ ការលើកសេចក្តីជំទាស់របស់មេធាវីការពារជនជាប់ចោទ អៀង សារី ទៅនឹងឯកសារទាំងអស់ខាងលើ (នៅក្នុងសវនាការពេលព្រឹក) និងការលើកសេចក្តី

00786741

ជំទាស់របស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ទៅនឹងឯកសារទាំងអស់ខាងលើ (នៅក្នុងសវនាការនាពេលរសៀល)

ថ្ងៃ ពុធ ទី ១៤ ខែ មីនា ឆ្នាំ ២០១២៖ ការលើកសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងឯកសារខាងលើ ដែលក្រុមមេធាវីការពារក្ដីបានស្នើសុំដាក់ (នៅក្នុងសវនាការពេលព្រឹកតាមការបែងចែកពេលវេលាដែលត្រូវឯកភាពដោយភាគីទាំងពីរ) និងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដី (សវនាការពេលរសៀល)

ថ្ងៃ ព្រហស្បត្តិ៍ ទី ១៥ ខែ មីនា ឆ្នាំ ២០១២៖ ចម្លើយតបរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដី (ពេញមួយថ្ងៃ)

ថ្ងៃ ច័ន្ទ ទី ១៩ ខែ មីនា ឆ្នាំ ២០១២៖ ចម្លើយតបរបស់ក្រុមមេធាវីការពារក្ដីទាំងអស់ ទៅនឹងសេចក្ដីជំទាស់របស់ភាគីផ្សេងៗ (ពេញមួយថ្ងៃប្រសិនបើចាំបាច់ តាមការបែងចែកពេលវេលាដែលត្រូវមានការឯកភាពក្នុងចំណោមក្រុមទាំងអស់)។

៦. អង្គជំនុំជម្រះបានទទួលសំណើរបស់សហព្រះរាជអាជ្ញា សុំស្ដាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 នៅចំពោះមុខអង្គជំនុំជម្រះ តាមរយៈប្រព័ន្ធសោតទស្សន៍ក្នុងអំឡុងសវនាការពេលព្រឹកនាដើមខែ មេសា ឆ្នាំ ២០១២ (ឯកសារ E166/1)។ ក្រុមមេធាវីការពារក្ដីមួយចំនួនបានជូនដំណឹងមកអង្គជំនុំជម្រះ អំពីចេតនារបស់ខ្លួនក្នុងការជំទាស់ទៅនឹងការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញតាមវិធីនេះ។ អង្គជំនុំជម្រះក៏បានទទួលសំណើមួយពីមេធាវីការពារជនជាប់ចោទ អៀង សារី ស្នើសុំទទួលយកឯកសារបន្ថែមពីអ្នកជំនាញរបស់អង្គជំនុំជម្រះ TC-38 នៅមុនពេលអ្នកជំនាញរូបនេះផ្ដល់សក្ខីកម្ម។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើនេះ (ឯកសារ E172/2 និងឯកសារ E172/3 ដាច់ដោយឡែកពីគ្នា)។ ដើម្បីអង្គជំនុំជម្រះមានលទ្ធភាពពិចារណាលើបញ្ហាអស់ទាំងនេះឲ្យបានទាន់ពេលវេលា អង្គជំនុំជម្រះនឹងស្ដាប់ការលើកទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងបញ្ហាទាំងនេះនៅវេលារសៀលថ្ងៃ ច័ន្ទ ទី ១៩ ខែ មីនា ឆ្នាំ ២០១២ (ប្រសិនបើកិច្ចដំណើរការនីតិវិធីដែលបានគ្រោងសម្រាប់ថ្ងៃនោះ បញ្ចប់មុនពេលកំណត់) ឬនៅវេលារសៀលថ្ងៃ អង្គារ ទី ២០ ខែ មីនា ឆ្នាំ ២០១២ វិញ។ អង្គជំនុំជម្រះសូមធ្វើការបែងចែកពេលវេលាសម្រាប់ភាគីដូចខាងក្រោម៖

00786742

សហព្រះរាជអាជ្ញា បន្ទាប់មកសហមេធាវីនាំមុខ (ស្តីពីសំណើរបស់សហព្រះរាជអាជ្ញាសុំស្តាប់សក្ខីកម្មអ្នកជំនាញ TCE-38 តាមរយៈប្រព័ន្ធសោតទស្សន៍ និងការជំទាស់ទៅនឹងឯកសារបន្ថែមដែលបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ) ៖ ៩០ នាទី

មេធាវីការពារជនជាប់ចោទ អៀង សារី (ស្តីពីសំណើសុំឯកសារបន្ថែមពីអ្នកជំនាញ និងការជំទាស់ទៅនឹងការស្តាប់សក្ខីកម្មរបស់អ្នកជំនាញតាមរយៈប្រព័ន្ធសោតទស្សន៍) និងក្រុមមេធាវីការពារក្តីនានាដែលចូលរួមសំណើ៖ ៩០ នាទី

សិទ្ធិក្នុងការឆ្លើយតបចំនួន ២០ នាទី (លើបញ្ហាទាំង២) នឹងត្រូវផ្តល់ជូនទៅសហព្រះរាជអាជ្ញា បន្ទាប់មកផ្តល់ជូនទៅមេធាវីការពារជនជាប់ចោទ អៀង សារី និងក្រុមមេធាវីការពារក្តីដែលចូលរួមសំណើ។

ការបែងចែកពេលវេលាជាក់លាក់រវាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ និងរវាងមេធាវីការពារជនជាប់ចោទ អៀង សារី និងក្រុមមេធាវីការពារក្តីដទៃទៀតដែលចូលរួមសំណើ នឹងត្រូវមានការឯកភាពគ្នាក្នុងចំណោមភាគីទាំងនោះ។

៧. សេចក្តីណែនាំបន្ថែមពាក់ព័ន្ធនឹងការពិភាក្សាអំពីឯកសារថ្មីៗទាំងឡាយដែលភាគីបានបង្ហាញ នឹងមាននៅពេលក្រោយ។ ប្រសិនបើចាំបាច់ អង្គជំនុំជម្រះក៏នឹងចេញសេចក្តីណែនាំពាក់ព័ន្ធនឹងឯកសារដែលមេធាវីការពារជនជាប់ចោទ នួន ជា បានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E131/1/13) និងឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធ A12 និង A13 បន្ទាប់ពីអង្គជំនុំ-ជម្រះសាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហាទាំងនេះ។ ភាគីនឹងត្រូវស្នើសុំឱ្យដាក់បន្ថែមនូវបញ្ជីឯកសាររបស់ខ្លួនសម្រាប់ខែ កក្កដា ឆ្នាំ ២០១១ នៅពេលក្រោយ ដែលពាក់ព័ន្ធនឹងផ្នែកបញ្ចប់នៃសវនាការលើសំណុំរឿង០០២/០១ (ឧទាហរណ៍ដូចជាការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ បន្ថែមពីលើចំណុចផ្សេងៗដែលអង្គជំនុំជម្រះអាចបញ្ជាក់ដោយខ្លួនឯងថាស្ថិតនៅក្នុងវិសាលភាពនៃសវនាការលើសំណុំរឿង ០០២/០១)។

៨. អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងទៅភាគីថាអនុលោមតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដែលមានចែងក្នុងវិធាន ៩១ *ស្ទួន* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះមានបំណង (បន្ទាប់ពីចៅក្រមបញ្ចប់ការសួរសំ

E172/5

ណ្ឌូរបឋម) ចាត់តាំងសហព្រះរាជអាជ្ញាឱ្យទទួលខុសត្រូវក្នុងការតាំងសំណួរទៅ កាំង ហ្កេកអ៊ាវ ហៅ *ឌុច* ព្រមទាំងការតាំងសំណួរទៅសាក្សីទាំងអស់ ពាក់ព័ន្ធនឹងប្រព័ន្ធទំនាក់ទំនងការងារ នៅក្នុងអនុស្សរណៈ E172 (តួយ៉ាងដូចជាសាក្សីដែលមានរហស្សនាម TCW-480 ដល់សាក្សីដែលមានរហស្សនាម TCW-398)។ បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងផ្តល់ឱកាសដល់ភាគីដទៃទៀតក្នុងការតាំងសំណួរទៅសាក្សីទាំងអស់ ដោយអនុវត្តតាមបែបបទជាប្រក្រតី។